# IV- ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៩៨

### សេចក្តីសំរេចលេខ ០០៤ សសរ.សហវ.ពដ

### ស្តីពី

### ការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

* * * *

### ទេសរដ្ឋមន្ត្រី

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រមលេខ នស.រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ១១ /នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ជស.រកម ០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

-បានឃើញច្បាប់ស្តីពីសារពើពន្ធដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

-បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

-បានឃើញប្រកាសលេខ ៣១៦ ប្រក.សហវ.ពដ. ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

-បានឃើញប្រកាសលេខ ២២៥ ប្រក.សហវ.ពដ. ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លី មិនបានប្រើប្រាស់

-បានឃើញប្រកាសលេខ ៧៤៥ ប្រក.សហវ.ពដ. ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់មេគុណសំរាប់អនុវត្តក្នុងការប្រមូលពន្ធលើដីធ្លី មិនបានប្រើប្រាស់

-បានឃើញប្រកាសលេខ ០២៦ ប្រក.សហវ.ពដ. ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីធ្លី មិនបានប្រើប្រាស់

-យោងតាមសំណើរបស់នាយកដ្ឋានពន្ធដារ

-យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។

**សំរេច**

ប្រការ១ : ដីធ្លីមិនបានប្រើប្រាស់ ស្ថិតនៅក្នុងខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើដីធ្លី មិនប្រើប្រាស់

ប្រការ២ : តម្លៃដីធ្លីសំរាប់ធ្វើជាមូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានកំណត់គិតជាតំលៃក្នុងមួយម៉ែត្រក្រឡា ទៅតាមតំបន់នីមួយៗ ដែលកំណត់ដោយគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

ប្រការ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា
**គាត ឈន់**

***

## ២-ធនាគារជាតិនៃកម្ពុជា

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៨

**ប្រកាស លេខ ធ ៩៩៨/៤១៥ ប្រក**

**ស្តីពីការប្រតពន្ធនជាប្រាក់បញ្ញើសំរាប់ប្រើប្រាស់ក្នុងស្រុក**
**របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**

* * * *

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា